# NSW FIRE BRIGADES

## និរភ័យភ្លើងឆេះនៅក្នុងផ្ទះបាយ-បញ្ជីផែកឆេះ

Fact Sheet 33 – Community Risk Management. Revised 1/11/2005

### ហេតុការណ៍ពិត

៩៥%នៃភ្លើងឆេះផ្ទះចាប់ផ្តើមពីផ្ទះបាយ។ នៅឆ្នាំ២០០៤/២០០៥ ក្រុមពន្លត់ភ្លើងរដ្ឋញូសៅវែលបានពន្លត់ភ្លើងឆេះនៅផ្ទះបាយចំនួន១៩៥៥ ដែលក្នុងចំនួននេះមានករណី៩៤៨ បណ្តាលមកពីពុំមានមនុស្សនៅចាំមើលពេលដាំស្ល។

ស្ថិតិនៃក្រុមពន្លត់ភ្លើងរដ្ឋញូសៅវែលត្រឹមត្រូវចាប់ពីថ្ងៃ៣០/៦/២០០៥

### តើផ្ទះបាយរបស់អ្នកផុតពីគ្រោះថ្នាក់ភ្លើងឆេះដែរឬទេ?

**ដើម្បីឲ្យរួចពីគ្រោះថ្នាក់ភ្លើងឆេះជាអតិបរិមានៅក្នុងផ្ទះបាយ យើងសូមផ្តាំផ្ញើឱវាទដូចខាងក្រោមនេះ៖**

- ភ្លើងអាចឆេះបាន នៅពេលដាំស្លដែលគ្មានមនុស្សនៅចាំមើល។ បើអ្នកត្រូវចេញទៅក្រៅនៅពេលកំពុងដាំស្ល ត្រូវបិទភ្លើងចង្ក្រាន
- នៅពេលដាំស្ល ត្រូវពាក់អាវដែលមានដៃអាវតឹង
- នៅពេលដាំស្ល កុំឲ្យកូនក្មេងមកក្បែរចង្ក្រាន។ គួរគិតគូរដាក់ប្រដាប់បាំងជើងក្រាន
- គួរដាក់កន្សែងជូតចាន ស្រោមដៃពាក់កាន់គ្រឿងប្រដាប់ក្តៅនិងរបស់ដែលអាចឆាបឆេះទាំងឡាយឲ្យនៅឆ្ងាយពីជើងក្រាន
- ប្រើប្រេងដាំស្លដោយប្រយ័ត្នប្រយែង ដាក់កំដៅវាយឺតៗ ហើយប្រើឆ្នាំងឲ្យសមទំហំ ដាក់ភ្លើងឲ្យខ្សោយដើម្បីជៀសវាងខ្លាញ់ខ្ទាត
- ដាក់ដៃឆ្នាំងឬខ្ទះចូលទៅក្នុង ដើម្បីកុំឲ្យមានការប៉ះទង្គិច
- លាងចង្កើរជើងក្រាននៅរាល់ពេលប្រើរួច ហើយសំអាតតម្រងប្រដាប់បឺតផ្សែង និងប្រដាប់ប្រដារដាំស្លនៅក្នុងផ្ទះបាយឲ្យបានទៀងទាត់
- ទឹកមិនអាចពន្លត់ភ្លើងឆេះដោយសារខ្លាញ់ឡើយ- កុំជះទឹកទៅលើខ្លាញ់កំពុងឆេះឲ្យសោះ។ ការជះទឹកទៅលើភ្លើងកំពុងឆេះរបៀបនេះអាចបណ្តាលឲ្យភ្លើងឆាបកាន់តែរហ័សថែមទៀត ហើយអាចបណ្តាលឲ្យមានរបួសរលាកកាន់តែខ្លាំងក្លាផង
- គួរដាក់គ្រឿងពន្លត់ភ្លើងនិងភួយពន្លត់ភ្លើងមួយនៅក្នុងផ្ទះបាយ ហើយឲ្យស៊ាំអំពីរបៀបប្រើរបស់ទាំងនោះ។ ត្រូវដាក់វាឲ្យនៅចម្ងាយមួយម៉ែត្រពីជើងក្រាននៅចន្លោះជើងក្រាននិងច្រកចេញដែលជិតជាងគេ
- គួរគិតគូរដាក់កំរាលជើងស្អិតនៅក្បែរជើងក្រាននិងកន្លែងលាងចានឆ្នាំង
- បើសិនជាមានខ្លាញ់ឆាបឆេះ ត្រូវបិទភ្លើងជើងក្រាន គ្របឆ្នាំង ឬប្រើភួយដើម្បីលត់ភ្លើង។ កុំកាន់ឆ្នាំងដែលមានប្រេងក្តៅឬឆេះដើរកាត់ក្នុងផ្ទះធ្វើដូច្នេះ នឹងបណ្តាលឲ្យភ្លើងឆាបឆេះ និងឲ្យមានរបួសកាន់តែខ្លាំងឡើងថែមទៀតផង។ ត្រូវទុកប្រេងឲ្យត្រជាក់មុននឹងដកគ្របចេញ ដោយសារថា ប្រេងអាចនឹងឆេះឡើងវិញ
- បើមានភ្លើងឆេះក្នុងផ្ទះបាយ ហើយដោយអ្នកមានអាយុកាន់តែច្រើន ឬដោយមូលហេតុផ្សេងៗទៀតនោះ អ្នកមិនមានទំនុកចិត្តលើខ្លួនឯងក្នុងការល្បងលត់ភ្លើង អ្នកត្រូវបិទពន្លត់គ្រឿងប្រដាប់ប្រដារ ដើរចេញហើយទូរស័ព្ទហៅក្រុមពន្លត់ភ្លើងលេខ 000 ពីកន្លែងទូរស័ព្ទណាមួយដែលឆ្ងាយពីកន្លែងគ្រោះថ្នាក់
- ត្រូវឲ្យប្រាកដថា អ្នកបានបិទគ្រឿងប្រដាប់ប្រដារដាំស្លនៅក្រោយពេលដែលប្រើប្រាស់រួច។

**សហការមួយរបស់ក្រុមពន្លត់ភ្លើងរដ្ឋញូសៅវែល ក្រុមពន្លត់ភ្លើងនៅជនបទរដ្ឋញូសៅវែល**
**ក្រុមពន្លត់ភ្លើងACT និង ក្រុមពន្លត់ភ្លើងនៅជនបទACT**

ចំពោះពត៌មានបន្ថែមទៀត សូមទាក់ទងនឹងស្ថានីយពន្លត់ភ្លើងនៅក្នុងដំបន់អ្នក ឬមណ្ឌលត្រួតត្រាភ្លើងឆេះ ឬ មើលគេហទំព័រ៖

www.fire.nsw.gov.au www.rfs.nsw.gov.au ឬ www.esa.act.gov.au

### ចំណុចសំខាន់ៗអំពីនិរភ័យឯទៀតៗ

- ត្រូវឲ្យប្រាកដថា គ្រឿងប្រដាប់ប្រដារប្រើខ្សែភ្លើងនៅប្រើការបានល្អប្រសើរ
- គ្រឿងឲ្យសញ្ញាពេលមានផ្សែងពិសេសសំរាប់ផ្ទះបាយមានដាក់លក់ គួរអ្នកគិតគូរតម្លើងមួយនៅក្នុងផ្ទះ ប៉ុន្តែត្រូវប្រយ័ត្នអំពីការឲ្យសញ្ញាខុសដោយសារមានផ្សែងមកពីការដាំស្ល។

**ពេលអាសន្ន សូមទូរស័ព្ទលេខ 000**